# អង្គការលើកលែងទោសអន្តរជាតិអំពាវនាវឱ្យរដ្ឋសមាជិកជ្រើសរើសចៅក្រម និងព្រះរាជអាជ្ញាដែលមានសមត្ថភាពខ្ពស់សម្រាប់អង្គជំនុំជម្រះវិសាមញ្ញនៅកម្ពុជា

*(សេចក្តីថ្លែងការណ៍សាធារណៈរបស់អង្គការលើកលែងទោសអន្តរជាតិ ថ្ងៃទី៤ ខែសីហា ឆ្នាំ២០០៥)*

នៅមិនដល់រយៈពេលមួយខែផងរហូតដល់ថ្ងៃបិទដំណើរការជ្រើសរើសចៅក្រមនិងព្រះរាជអាជ្ញាសម្រាប់អង្គជំនុំជម្រះវិសាមញ្ញដើម្បីកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជានូវឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលកម្ពុជាប្រជាធិបតេយ្យ អង្គការលើកលែងទោសអន្តរជាតិកំពុងតែអំពាវនាវឲ្យរដ្ឋទាំងឡាយជ្រើសរើសបេក្ខភាពដែលមានសមត្ថភាពខ្ពស់បំផុតសម្រាប់បម្រើការងារនៅក្នុងអង្គជំនុំជម្រះវិសាមញ្ញនេះ ។

អង្គការលើកលែងទោសអន្តរជាតិបានចាប់ផ្តើមយុទ្ធនាការរបស់ខ្លួនក្នុងការស្វែងរកយុត្តិធម៌សម្រាប់ជនរងគ្រោះនៃរបបខ្មែរក្រហមតាំងពីឆ្នាំ១៩៧៨មកម្ល៉េះ ។ បើទោះបីជាអង្គការនេះស្វាគមន៍ការបង្កើតអង្គជំនុំជម្រះវិសាមញ្ញថាជាជំហានមួយដ៏សំខាន់សម្រាប់នាំទៅកាន់តុលាការនូវបុគ្គលមួយចំនួនដែលទទួលខុសត្រូវខ្ពស់បំផុតឲ្យចំពោះឧក្រិដ្ឋកម្មរបស់របបខ្មែរក្រហមក៏ដោយ ក៏អង្គការនេះបានសម្តែងនូវការព្រួយបារម្ភជាខ្លាំងអំពីធាតុផ្សំខ្លះដែលមានចែងនៅក្នុងកិច្ចព្រមព្រៀងបង្កើតអង្គជំនុំជម្រះវិសាមញ្ញ ។

បើពិនិត្យមើលទៅលើភាពទន់ខ្សោយយ៉ាងខ្លាំងរបស់ប្រព័ន្ធយុត្តិធម៌ក្នុងស្រុក អង្គការលើកលែងទោសអន្តរជាតិស្រងាកចិត្តចំពោះសេចក្តីសម្រេចក្នុងការតែងតាំងចៅក្រមកម្ពុជាភាគច្រើនឲ្យបម្រើការនៅក្នុងអង្គជំនុំជម្រះវិសាមញ្ញនេះ ។ ចៅក្រមចំនួន ១១រូបនៅក្នុងចំណោមចៅក្រម១៩រូប និងសហព្រះរាជអជ្ញាមួយរូបនៅក្នុងចំណោមពីររូបជាជនជាតិកម្ពុជា ។

ដោយបានសង្កេតនិងផ្តល់យោបល់ទាក់ទងនឹងប្រព័ន្ធយុត្តិធម៌ជាតិអស់រយពេលជាច្រើនឆ្នាំ អង្គការលើកលែងទោសអន្តរជាតិយល់ឃើញថា ប្រព័ន្ធយុត្តិធម៌របស់កម្ពុជានៅតែទន់ខ្សោយហើយទទួលរងនូវឥទ្ធិពលនយោបាយជាពិសេសនៅក្នុងសំណុំរឿងធំៗ ។ សម្រាប់រយៈពេលបច្ចុប្បន្ននេះ វាមិនអាចធានាទេថាសវនាការនឹងត្រូវបានប្រព្រឹត្តទៅតាមរបៀបមួយដែលស្របតាមច្បាប់និងបទដ្ឋានអន្តរជាតិនៃយុត្តិធម៌នោះទេ ។

តួនាទីរបស់ចៅក្រមអន្តរជាតិទាំង៨រូបនិងសហព្រះរាជអាជ្ញាអន្តរជាតិនឹងមានសារសំខាន់ជាខ្លាំងក្នុងការបំពេញការងារជាមួយបុគ្គលិកជនជាតិកម្ពុជាដើម្បីធានាថាអង្គជំនុំជម្រះវិសាមញ្ញបំពេញបានតាមបទដ្ឋានខ្ពស់បំផុតនៃយុត្តិធម៌អន្តរជាតិ ដោយរួមទាំងការគោរពយ៉ាងពេញលេញនូវសិទ្ធិទទួលបានការជំនុំជម្រះសេចក្តីដោយយុត្តិធម៌ និងធានាឲ្យបាននូវវិធានការការពារដ៏មានប្រសិទ្ធិភាពចំពោះជនរងគ្រោះនិងសាក្សី ។

វាមានសារសំខាន់បំផុតដែលរដ្ឋាភិបាលនៅជុំវិញពិភពលោកពិចារណាអំពីការជ្រើសរើសបេក្ខភាពមានសមត្ថភាពខ្ពស់បំផុតនៅក្នុងប្រទេសរបស់ខ្លួនសម្រាប់តួនាទីនៅក្នុងអង្គជំនុំជម្រះវិសាមញ្ញ ។ ជាការពិត អង្គការលើកលែងទោសអន្តរជាតិបានចេញសេចក្តីអំពាវនាវស្រដៀងគ្នានេះម្តងរួចហើយទាក់ទងនឹងការជ្រើសរើសចៅក្រមនិងព្រះរាជអាជ្ញាសម្រាប់តុលាការព្រហ្មទណ្ឌអន្តរជាតិ ។

ជនរងគ្រោះរាប់លាននាក់នៃឧក្រិដ្ឋកម្មដែលស្ថិតនៅក្រោមច្បាប់អន្តរជាតិដែលប្រព្រឹត្តដោយខ្មែរក្រហម និងក្រុមគ្រួសាររបស់អ្នកទាំងនោះបានរង់ចាំទទួលយុត្តិធម៌អស់រយៈពេលយូរពេកហើយ ។ ប្រសិនបើចង់ឲ្យអង្គជំនុំជម្រះវិសាមញ្ញនេះទទួលបានជោគជ័យ សហគមន៍អន្តរជាតិត្រូវតែគាំទ្រយ៉ាងពេញទំហឹងចំពោះដំណើរការនេះ ។

## ប្រវត្តិ

កាលពីថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០០៣ អង្គការសហប្រជាជាតិនិងរាជរដ្ឋាភិបាលកម្ពុជាបានព្រមព្រៀងគ្នាដើម្បីបង្កើត

អង្គជំនុំជម្រះវិសាមញ្ញ ។ អង្គជំនុំជម្រះវិសាមញ្ញនឹងបង្កើតជាតុលាការដែលមានការចូលរួមរបស់អន្តរជាតិ ដោយផ្អែកលើច្បាប់ជាតិនិងច្បាប់អន្តរជាតិដើម្បីស៊ើបអង្កេតនិងជំនុំជម្រះមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមនិងអ្នកទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម និងការរំលោភធ្ងន់ធ្ងរទៅលើច្បាប់ព្រហ្មទណ្ឌកម្ពុជា ច្បាប់មនុស្សធម៌អន្តរជាតិ និងច្បាប់ទំនៀមទម្លាប់ និងអនុសញ្ញាអន្តរជាតិដែលទទួលស្គាល់ដោយភាគីកម្ពុជា និងដែលត្រូវបានប្រព្រឹត្តឡើងនៅក្នុងអំឡុងពេលពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ រហូតដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩ ។

កិច្ចព្រមព្រៀងបានរៀបចំអង្គជំនុំជម្រះដូចខាងក្រោមៈ អង្គជំនុំជម្រះនៃសាលាដំបូង មានចៅក្រមកម្ពុជាចំនួន៣រូប និងចៅក្រមអន្តរជាតិចំនួន២រូប អង្គជំនុំជម្រះនៃសាលាកំពូល មានចៅក្រមកម្ពុជាចំនួន៤រូបនិងចៅក្រមអន្តរជាតិចំនួន៣រូប បុរេអង្គជំនុំជម្រះវិសាមញ្ញមានចៅក្រមកម្ពុជា៣រូបនិងចៅក្រមអន្តរជាតិចំនួន២រូប ចៅក្រមស៊ើបអង្កេតកម្ពុជាមួយរូបនិងអន្តរជាតិមួយរូប និងព្រះរាជអាជ្ញាកម្ពុជាមួយរូបនិងអន្តរជាតិមួយរូប ។ ក្រុមប្រឹក្សានៃអង្គចៅក្រមកម្ពុជាជាអ្នកជ្រើសរើសចុងក្រោយ ។ ចំពោះតំណែងសម្រាប់បុគ្គលិកអន្តរជាតិ ក្រុមប្រឹក្សានៃអង្គចៅក្រមកម្ពុជាជ្រើសរើសចេញពីបេក្ខភាពដែលត្រូវបានជ្រើសរើសដោយអគ្គលេខាធិការអង្គការសហប្រជាជាតិ ។

នៅក្នុងអត្ថបទដែលមានចំណងជើងថា «ព្រះរាជាណាចក្រកម្ពុជាៈ តួនាទីនិងការព្រួយបារម្ភរបស់អង្គការលើកលែងទោសអន្តរជាតិទាក់ទងនឹងសាលាជំនុំជម្រះក្តីខ្មែរក្រហម» ដែលចេញផ្សាយកាលពីថ្ងៃទី២៥ ខែមេសា ឆ្នាំ២០០៣ អង្គការលើកលែងទោសអន្តរជាតិបានសម្តែងនូវការព្រួយបារម្ភអំពីអង្គជំនុំជម្រះវិសាមញ្ញ ។ បើទោះបីជាមានការអភិវឌ្ឍជាបន្តបន្ទាប់ស្ទើរតែទាំងអស់នៃការព្រួយបារម្ភឲ្យដែលមានសរសេរនៅក្នុងអត្ថបទខាងលើទាំងនេះអំពីអង្គជំនុំជម្រះវិសាមញ្ញនៅតែមានដដែល ប៉ុន្តែគេសង្ឃឹមថា ការជ្រើសរើសបេក្ខជនផ្សេងៗដែលមានលក្ខណសម្បត្តិគ្រប់គ្រាន់សម្រាប់ធ្វើជាចៅក្រមនិងសហព្រះរាជអាជ្ញានឹងអាចដោះស្រាយការព្រួយបារម្ភខ្លះក្នុងចំណោមការព្រួយបារម្ភទាំងនេះមិនខាន ។

នៅក្នុងអំឡុងពេលនៃការគ្រប់គ្រងរបស់របបខ្មែរក្រហម ប្រព័ន្ធតុលាការជាតិត្រូវបានបោះបង់ចោលទាំងស្រុង ។ ភាគច្រើននៃចៅក្រមនិងមេធាវីដែលស្ថិតនៅក្នុងប្រទេសនៅពេលនោះ ត្រូវបានសម្លាប់ឬបានស្លាប់ដោយមូលហេតុផ្សេងៗ ។ ក្នុងចំណោមអ្នកដែលនៅរស់រានមានជីវិតភាគច្រើនបានភៀសខ្លួនទៅបរទេសកាលពីថ្ងៃទី២៥ ខែធ្នូ ឆ្នាំ១៩៧៨ នៅពេលដែលកងទ័ពវៀតណាមចូលប្រទេសកម្ពុជា ។ នៅពេលដែលរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យដួលរលំកាលពីថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ ក្នុងប្រទេសសល់មេធាវីដែលមានសមត្ថភាពតែចំនួន១០នាក់ប៉ុណ្ណោះ ។ ប្រព័ន្ធយុត្តិធម៌កម្ពុជានៅតែមានសម្ពារអន់ថយ ប្រាក់បៀវត្សរ៍ទាប ការជ្រៀតជ្រែករបស់អំណាចនីតិបញ្ញត្តិ ខ្វះខាតការអប់រំនិងការហ្វឹកហ្វឺន និងការអនុវត្តច្បាប់មានលក្ខណៈទន់ខ្សោយ ។

នៅអំឡុងពេលនៃការរៀបចំកិច្ចព្រមព្រៀងបង្កើតអង្គជំនុំជម្រះវិសាមញ្ញ អគ្គលេខាធិការអង្គការសហប្រជាជាតិបានកត់សម្គាល់នៅក្នុងរបាយការណ៍ទៅកាន់អង្គមហាសន្និបាតថា «ខ្ញុំនឹកឃើញដល់របាយការណ៍ (របាយការណ៍របស់អគ្គលេខាធិការអង្គការសហប្រជាជាតិស្តីអំពីសាលាជំនុំជម្រះក្តីខ្មែរក្រហម, ឯកសារអង្គការសហប្រជាជាតិ *UN Doc. A/57/769* ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៣, កថាខណ្ឌ ២៨) របស់អ្នកតំណាងពិសេសទទួលបន្ទុកសិទ្ធិមនុស្សប្រចាំនៅប្រទេសកម្ពុជាដែលបានរកឃើញថា តុលាការកម្ពុជាមានការគោរពតិចតួចប៉ុណ្ណោះចំពោះខ្លឹមសារសំខាន់ៗអំពីសិទ្ធិដើម្បីទទួលបាននូវការជំនុំជម្រះក្តីដោយយុត្តិធម៌ ។ ខ្ញុំមានការព្រួយបារម្ភថា ខចែងសំខាន់ៗរបស់កិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលកម្ពុជានិងអង្គការសហប្រជាជាតិដើម្បីបង្កើតអង្គជំនុំជម្រះវិសាមញ្ញ ប្រហែលជានឹងមិនត្រូវបានគោរពឲ្យបានពេញលេញនៅក្នុងអង្គជំនុំជម្រះវិសាមញ្ញនោះទេ និងថាបទដ្ឋានយុត្តិធម៌អន្តរជាតិនិងដំណើរការត្រឹមត្រូវតាមផ្លូវច្បាប់មិនអាចត្រូវបានធានា» ។